ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨

## Budget Strategic Plan 2026-2028

ក្រុមការងាររៀបចំផែនការថវិកា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រាជធានីភ្នំពេញ ខែមិថុនា ឆ្នាំ២០២៥

# មាតិកា

**១. សេចក្តីផ្តើម** ....... 1

១.១ តួនាទី និងបេសកកម្ម ....... 2

១.១.១ ចក្ខុវិស័យ ....... 2

១.១.២.បេសកកម្ម ....... 3

១.១.៣. គោលបំណង ....... 3

១.១.៤. គោលដៅ ....... 3

១.២. លទ្ធផលសម្រេចបានឆ្នាំ២០២៤ ....... 3

១.២.១ ស្ថានភាពវិស័យកសិកម្មឆ្នាំ២០២៤ ....... 3

១.២.២. ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ....... 3

១.២.៣ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ ....... 4

១.២.៤. ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ....... 6

១.២.៥. ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ ....... 6

១.២.៦. ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ....... 6

១.៣. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ....... 7

១.៤ បញ្ហាប្រឈម ....... 7

១.៥. វិធានការ ....... 8

**២. គោលបំណងគោលនយោបាយ** ....... 9

**៣. ការរៀបចំកម្មវិធី** ....... 10

កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម ....... 10

កម្មវិធីទី២៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម ....... 10

កម្មវិធីទី៣៖ ការពង្រឹងស្ថាប័ន និងកិច្ចការទូទៅ ....... 10

**៤. ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម** ....... 14

៤.១. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ ....... 14

៤.២. ទម្រង់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម ....... 23

**៥. ការកំណត់ធនធាន** ....... 79

៥.១ ការគ្រោងចំណូល ........ 79

៥.២ ការកំណត់តម្រូវការចំណាយ ........ 83

**៦. សេចក្តីសន្និដ្ឋាន** ........ 103

# ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញទិសដៅជាយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០ ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមជ្ឈការទៅរកប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្មនិងវិមជ្ឈការ។ បន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ នៃកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៨-២០២៥ គឺផ្តោតលើប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។

ផ្អែកតាមទិសដៅនៃកម្មវិធីកែទម្រង់នេះ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំស្របតាមខ្លឹមសារនៃសារាចរណែនាំលេខ ០៨សរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ដែលគ្របដណ្តប់ថវិកាទាំងអង្គភាពបច្ចេកទេសថ្នាក់កណ្តាល គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តទាំង២៥។

នៅគ្រប់ដំណាក់កាលទាំងអស់ រាជរដ្ឋាភិបាលតែងតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដ៏សំខាន់មួយ ដែលចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ជនបទ លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦សម្រាប់វិស័យកសិកម្ម កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹង (១) លើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន ១០០លានដុល្លារអាមេរិក ដែលនឹងសម្រួលដល់ខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម និងធានាតុល្យភាពនៃការផ្គត់ផ្គង់និងតម្រូវការ ដើម្បីគាំទ្រដល់ការផលិតរបស់កសិករ ក៏ដូចជាតម្រូវការស្បៀងអាហាររបស់ប្រជាពលរដ្ឋកម្ពុជា (២) ដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងកង្វះបច្ចេកទេសរបស់កសិករ និងសហគមន៍នៅមូលដ្ឋាន ជួយតម្រង់ទិសដល់កសិករក្នុងផលិតកម្មកសិកម្ម និងជួយសម្របសម្រួលក្នុងការស្វែងរកទីផ្សារជូនកសិករពេលប្រមូលផល និង(៣) អភិវឌ្ឍន៍សហគមន៍កសិកម្មទំនើប ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងផលិតកម្មកសិកម្មប្រកបដោយប្រសិទ្ធភាព និងមានសេដ្ឋកិច្ចមាត្រដ្ឋាន តាមរយៈការប្រមូលផ្តុំការប្រើប្រាស់ដីផលិតកម្មក្នុងទំហំមួយសមស្របដល់ការប្រើប្រាស់មធ្យោបាយទំនើប កាត់បន្ថយថ្លៃដើមផលិតកម្ម បង្កើនផលិតភាព បង្កើនផលចំណេញ និងបែងចែកផលលាភជូនកសិករប្រកបដោយតម្លាភាព និងសមធម៌។

ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំថវិកា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែសម្រួលនូវសមាសភាពក្រុមការងារចំនួន២ គឺៈ (១)ក្រុមការងាររៀបចំថវិកា និង(២)ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ដែលក្រុមទាំង២នេះ ដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពចម្រុះពីអង្គភាពសំខាន់ៗ ពិសេសពីនាយកដ្ឋានផែនការ និងស្ថិតិ និងនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ។

ម៉្យាងវិញទៀត ផ្អែកក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបង្ហាញច្បាស់លាស់ក្នុងឯកសារនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រថវិកា២០២៦-២០២៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏ត្រូវបានរៀបចំឡើងដោយមានសង្គតិភាពជាមួយគោលនយោបាយខាងលើ ដែលជាមូលដ្ឋានសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព។

រចនាសម្ព័ន្ធឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំជា៦ផ្នែកសំខាន់ៗ រួមមានៈ

**ផ្នែកទី១៖** បង្ហាញពីតួនាទីនិងបេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងមក បញ្ហាប្រឈម និងវិធានការគោលនយោបាយសំខាន់ៗសម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

**ផ្នែកទី២៖** ការកំណត់គោលបំណងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបង្ហាញពីចក្ខុវិស័យរយៈពេលមធ្យមនិងវែង ផ្អែកលើយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

**ផ្នែកទី៣៖** ការរៀបចំកម្មវិធីថ្មីទាំង៣របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួងដូចដែលបានរៀបរាប់ក្នុងផ្នែកទី២ខាងលើ ដែលកម្មវិធីទាំង៣នេះមានលក្ខណៈសមាហរណកម្ម និងគ្របដណ្តប់លើគម្រោង/សកម្មភាពការងារទាំងអស់ ដោយរាប់បញ្ចូលទាំងគម្រោង/សកម្មភាពការងារដែលផ្តល់ហិរញ្ញប្បទានពីថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា ហើយផ្នែកនេះក៏នឹងបង្ហាញពីតម្រូវការធនធាន សម្រាប់អនុវត្តដែលរួមទាំងថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍ផងដែរ។

**ផ្នែកទី៤៖** ការកំណត់សូចនាករ និងគោលដៅសូចនាករ ដែលជាមូលដ្ឋានសម្រាប់ការតាមដាន និងវាយតម្លៃនៃការអនុវត្តកម្មវិធីទាំង៣របស់ក្រសួង។

**ផ្នែកទី៥៖** ការកំណត់តម្រូវការចំណាយសម្រាប់អនុវត្តរយៈពេល៣ឆ្នាំ (២០២៦-២០២៨) តាមកម្មវិធីនីមួយៗ និងការគ្រោងចំណូលផ្អែកលើលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក។

**ផ្នែកទី៦៖** ផ្នែកចុងក្រោយដែលបង្ហាញពីសេចក្តីសន្និដ្ឋាន លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ ការលើកទិសដៅ និងវិធានការនានា ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកានេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិនិត្យ និងវាយតម្លៃអង្គភាពក្រោមឱវាទ តាមលក្ខខណ្ឌវិនិច្ឆ័យទាំង៧ នៃអង្គភាពថវិកា និងបានកំណត់អង្គភាពថវិកាចំនួន៤៦ ដែលត្រូវយកទៅអនុវត្តកន្លងមក ក្នុងនោះ អង្គភាពថ្នាក់កណ្តាលចំនួន២១អង្គភាព និងថ្នាក់រាជធានី ខេត្ត (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត) ចំនួន២៥អង្គភាព។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាពឱ្យអង្គភាពថវិកាទាំង៤៦នេះ បានដំណើរការអនុវត្តការងាររបស់ខ្លួន។ ទន្ទឹមនេះ ក្រសួងបានដាក់អង្គភាពថវិកាចំនួន៥ ឱ្យក្លាយទៅជាអង្គភាពថវិកាពេញលេញចាប់ពីឆ្នាំ២០២៥ នេះ។

## ១.១ តួនាទី និងបេសកកម្ម

ទស្សនវិស័យ បេសកកម្ម និងភារកិច្ចចម្បងៗសម្រាប់ឆ្នាំ២០២៦-២០២៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានដូចខាងក្រោម៖

### ១.១.១ ចក្ខុវិស័យ

បន្តធានាសន្តិសុខស្បៀងកម្ពុជាប្រកបដោយ និរន្តរភាព សេដ្ឋកិច្ច និងបរិស្ថាន ហើយកសិកម្មនៅតែចូលរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិ។

#### ១.១.២.បេសកកម្ម

ដឹកនាំវិស័យកសិកម្ម ដើម្បីសម្រេចចក្ខុវិស័យខាងលើ តាមរយៈការស្រាវជ្រាវ និងផ្តល់បច្ចេកទេសកសិកម្ម គ្រប់គ្រងធនធានធម្មជាតិ បណ្តុះបណ្តាលធនធានមនុស្ស កសាង និងពង្រឹងមូលដ្ឋានគតិយុត្តកសិកម្ម និងដាក់ចេញនូវវិធានការសេដ្ឋកិច្ច ដើម្បីគាំទ្រ សម្របសម្រួល និងតម្រង់ទិសខ្សែច្រវាក់ផលិតកម្ម។

#### ១.១.៣. គោលបំណង

ពង្រឹងប្រសិទ្ធភាពខ្សែច្រវាក់ផលិតកម្មកសិកម្ម ប្រកបដោយនិរន្តរភាពដើម្បីធានាសន្តិសុខស្បៀង និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។

#### ១.១.៤. គោលដៅ

- កសាងសហគមន៍កសិកម្មទំនើប
- សេវាទ្រទ្រង់បច្ចេកទេសកសិកម្មបានទៅដល់កសិករ
- រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ
- ថែរក្សា និងគ្រប់គ្រងធនធានធម្មជាតិកសិកម្ម។

### ១.២. លទ្ធផលសម្រេចបានឆ្នាំ២០២៤

#### ១.២.១ ស្ថានភាពវិស័យកសិកម្មឆ្នាំ២០២៤

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ១៦,៧% (គិតជាតម្លៃបច្ចុប្បន្ន) ក្នុងផលិតផលសរុបក្នុងស្រុកសម្រាប់ ឆ្នាំ២០២៤ ដោយមានការផ្លាស់ប្តូរឆ្នាំគោល ២០០០ មកឆ្នាំ២០១៤។ បើគិតជាតម្លៃថេរ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ១៤,២% នៃផលិតផលសរុបក្នុងស្រុកសម្រាប់ឆ្នាំ២០២៤។

តម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (Gross Value Added in Agriculture) មានការកើនឡើងជារៀងរាល់ឆ្នាំពី ២៤ ២៨២ពាន់លានរៀល នៅឆ្នាំ២០២០ ដល់ ៣១ ២៩២ពាន់លានរៀល នៅឆ្នាំ២០២៤ (គិតជាតម្លៃបច្ចុប្បន្ន)។

#### ១.២.២. ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច

**ផ្នែកដំណាំ៖**

- ផ្ទៃដីដាំដុះដំណាំស្រូវកើនពី ៣,៤០៤លានហិកតា នៅឆ្នាំ២០២០ ដល់ ៣,៨៦លានហិកតា នៅឆ្នាំ២០២៤ កំណើនជាមធ្យមប្រមាណ ៣,០៧%។ បរិមាណផលស្រូវកើនពី ១០,៩៤លានតោន ដល់ប្រមាណជា ១៣,៨៩លានតោន និងទិន្នផលស្រូវកើនពី ៣,៣៥តោន/ហិកតា ដល់ប្រមាណជា ៣,៦៤តោន/ហិកតា។
- ផលិតកម្មដំណាំសាកវប្បកម្មសំខាន់ៗរួមមាន បន្លែគ្រប់ប្រភេទ ដំណាំហូបផ្លែ និងរុក្ខជាតិលម្អ។ ផ្ទៃដីដាំដុះដំណាំសាកវប្បកម្មមានចំនួន ០,៣១លានហិកតា នៅឆ្នាំ២០២០ ដល់ប្រមាណជា ០,៣៤ លានហិកតា នៅឆ្នាំ២០២៤ (កំណើនជាមធ្យមប្រចាំឆ្នាំ ២,៥%) និងបរិមាណផលបានកើនពី ៣,៦៨លានតោន នៅឆ្នាំ២០២០ ដល់ប្រមាណជា ៥,១៥លានតោន នៅឆ្នាំ២០២៤ (មានកំណើនជាមធ្យមប្រចាំឆ្នាំ ១២,២៩%)។
- ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មកើនពី ១,២៩លានហិកតា នៅឆ្នាំ២០២០ ដល់ ១,៧៩លានហិកតា នៅឆ្នាំ២០២៤ (មានកំណើនជាមធ្យមប្រមាណ៨,៤៨%) និងបរិមាណផលបានកើនពី ១៥,០៩លានតោន ដល់ប្រមាណ ២០,០៥លានតោន។

- ឆ្នាំ២០២៤ សហគមន៍កសិកម្មសរុបចំនួន ១ ៤៧៥សហគមន៍ ក្នុងនោះក៏មានសហគមន៍កសិកម្មទំនើបចំនួន ៩សហគមន៍ក្នុងខេត្តចំនួន៦ ផងដែរ។ ដោយមានដើមទុនប្រមាណ ១០៦,៦៨ពាន់លានរៀល។ សហគមន៍កសិកម្មចំនួន ១៥៨ ក្រុមកសិករនិងបណ្តុំអាជីវកម្មចំនួន៨២ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន ៧១ក្រុមហ៊ុន សរុបកសិករចូលរួមចំនួន ១៥ ០៦៥គ្រួសារ លើផ្ទៃដីសរុប ២៦ ៧៧៥,៤៦ហិកតា ក្នុងបរិមាណសរុបចំនួន ១ ៤៣៧ ៩០៣,០២តោន ១ ១០១ ៦០០គ្រាប់ និង ៥៩៥ ២០០លីត្រ។

## ដំណាំកៅស៊ូ៖

- ផ្ទៃដីកៅស៊ូកម្ពុជាសរុបបានកើនឡើងពីចំនួន ៤០៤,១៣ន់ហិកតា នៅឆ្នាំ២០២០ ដល់ ៤២៥,៤ ពាន់ហិកតា នៅឆ្នាំ២០២៤ (កំណើនជាមធ្យមប្រមាណ១,៣២%) ដែលក្នុងនោះផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន២០២,៣ពាន់ហិកតា ស្មើនឹង៤៨%។
- ផ្ទៃដីកៅស៊ូយកផលកើនឡើងពី ២៩២,៥ពាន់ហិកតា នៅឆ្នាំ២០២០ ដល់ ៣៣០,៤ពាន់ហិកតា នៅឆ្នាំ ២០២៤ (កើនឡើងប្រមាណ១២,៤% ។ ផលិតផលកៅស៊ូសរុបបានកើនឡើងពី ៣៤៩,៣ពាន់តោន នៅឆ្នាំ២០២០ ដល់ ៤០៧,២ពាន់តោន នៅឆ្នាំ២០២៤ (កំណើនជាមធ្យមប្រមាណ៣,៩១%)។
- ក្នុងឆ្នាំ២០២៤ ចំណូលសរុបទទួលបានពីការលក់ផលិតផលកៅស៊ូមានប្រមាណចំនួន ៦៦៣,៦ លានដុល្លារអាមេរិក កើនឡើងប្រមាណចំនួន ១២៤,២លានដុល្លាអាមេរិក ស្មើនឹង២៣% ធៀបឆ្នាំ ២០២៣ ក្នុងនោះរួមមាន៖ (១)ការនាំចេញកៅស៊ូ សម្រេចបានចំនួន ៣៣៨ ០០០តោន គិតជាទឹកប្រាក់ប្រមាណចំនួន ៥៦១,៨លានដុល្លារអាមេរិក ថយចុះចំនួន ៣០ ០៤៨តោន ស្មើនឹង -៨,២% និងប្រាក់ចំណូលពីការនាំចេញកៅស៊ូកើនឡើងប្រមាណចំនួន ៦៩,៧លានដុល្លារអាមេរិក ស្មើនឹង ១៤,២% ធៀបឆ្នាំ២០២៣ (២)ការនាំចេញឈើកៅស៊ូមានចំនួន ២៥ ១៥៧ម៉ែត្រគូប គិតជាទឹកប្រាក់ប្រមាណចំនួន ៥,៤លានដុល្លារអាមេរិក បានកើនឡើង ១៥ ៧៤៦ម៉ែត្រគូប និងទឹកប្រាក់កើនឡើងចំនួន ៣,៨ លានដុល្លារអាម៉េរិក ស្មើនឹង២៤០,៦% ធៀបនឹងឆ្នាំ២០២៣ និង(៣)ការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកចំនួន ៥៨ ០០០តោន គិតជាទឹកប្រាក់ប្រមាណចំនួន ៩៦,៤លានដុល្លារអាមេរិក បានកើនឡើងចំនួន ២៧ ៥៤៨ម៉ែត្រគូប និងទឹកប្រាក់កើនឡើងចំនួន ៥០,៧លានដុល្លាអាមេរិក ស្មើនឹង ១១១% ធៀបនឹងឆ្នាំ២០២៣។

## ការនាំចេញកសិផលឆ្នាំ២០២៣

ឆ្នាំ២០២៤ កម្ពុជាបាននាំចេញកសិផលទៅក្រៅប្រទេសសរុបចំនួន ១២ ០០២ ៣០០តោន ក្នុងនោះ អង្កចំនួន៦៤៥ ៨៧២តោន ស្រូវចំនួន៤ ៦០៨ ៥៧៤តោន និងកសិផលក្រៅពីស្រូវ-អង្ករចំនួន ៦ ៧៤៧ ៨៥៥តោន ទៅ ១២២ប្រទេស មានការកើនឡើងចំនួន៤២% ធៀបនឹងឆ្នាំ២០២៣។ ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ដែលទទួលបានពីការនាំចេញកសិផលឆ្នាំ២០២៤ ចំនួន ៥,៣ ពាន់លានដុល្លារអាមេរិក ក្នុងនោះ អង្ករចំនួន ៥៦៧ ៧១៩ ៣៩៥ដុល្លាអាមេរិក ស្រូវចំនួន ៩៣៩ ៩៦៥ ៦៨២ដុល្លាអាមេរិក និងកសិផលក្រៅពីស្រូវ-អង្ករចំនួន ២ ៧៩៩ ១២៥ ១៩១,៥០ដុល្លាអាមេរិក (ផ្អែកតាមវិក្កយបត្រនាំចេញ)។

## ១.២.៣ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក្នុងឆ្នាំ២០២៤ មានសត្វសរុបចំនួន ៣៩,៨លានក្បាល ក្នុងនោះ គោចំនួនប្រមាណ ៣លានក្បាល ក្របីចំនួន ៤៥០,៧៨ពាន់ក្បាល ជ្រូកចំនួន ១,២៦លានក្បាល បក្សីចំនួន ៣៥,០២

លានក្បាល សេះចំនួន ៣,១១ពាន់ក្បាល ចៀមចំនួន ៧,៥ពាន់ក្បាល ពពែចំនួន ៥៦,៨៦ពាន់ក្បាល និងដំរីចំនួន ៣៦ក្បាល។

ប្រៀបធៀបឆ្នាំ២០២៣ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបមានអត្រាកំណើន ១,៧% ក្នុងនោះ គោថយចុះ -0,៦% ក្របីកើន ៤,៥% សេះកើន ១១,៩% ជ្រូកកើន ១,៦% បក្សីកើន ១,៨% ចៀមកើន ៧៤,៣% និងពពែកើន ១០,១%។ ក្នុងឆ្នាំ២០២៤ ការសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម មានចំនួនសរុប ២៩,៥១លានក្បាល ក្នុងនោះ គោ-ក្របីចំនួន ៥៤,៥៤ពាន់ក្បាល ជ្រូកចំនួន ២,៨០លានក្បាល បក្សីចំនួន ២៦,៥៤លានក្បាល សេះចំនួន ២០ក្បាល ចៀមចំនួន ១,០៧ពាន់ក្បាល ពពែចំនួន ៣,៤៦ពាន់ក្បាល និងស្វាចំនួន ១០២,៨១ពាន់។

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់បរិភោគ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពីចំនួន ៣០១ពាន់តោន ក្នុងឆ្នាំ២០២០ ឡើងដល់ចំនួន ៣៣១ពាន់តោន នៅឆ្នាំ២០២៤។ ដោយឡែកក្នុងឆ្នាំ២០២៤ នេះ តម្រូវការសាច់សរុបចំនួន ៣៣១ពាន់តោន ក្នុងនោះសាច់គោ-ក្របីចំនួន ៩២ពាន់តោន សាច់ជ្រូកចំនួន ១៦៧ពាន់តោន សាច់បក្សីចំនួន ៧០,៧ពាន់តោន និងសាច់ចៀម-ពពែឬសាច់ផ្សេងៗទៀតចំនួន ៨៩៥តោន។

ផលិតកម្មសត្វក្នុងស្រុកអាចផ្គត់ផ្គង់សាច់បានប្រមាណ ៣២៥ពាន់តោន ស្មើនឹង ៩៨,១% នៃតម្រូវការសរុប ក្នុងនោះសាច់គោ-ក្របីចំនួន ៩០,៧ពាន់តោន (៨២៥ពាន់ក្បាល) សាច់ជ្រូកចំនួន ១៦៧ពាន់តោន (៣,៣៥ លានក្បាល) សាច់បក្សីចំនួន ៦៦ពាន់តោន (៥៥,១៥៧ពាន់ក្បាល)។ ដើម្បីបង្គ្រប់តម្រូវការនៅក្នុងឆ្នាំ ២០២៤ កម្ពុជា បាននាំចូលសាច់ និងផលិតសត្វសរុបចំនួន ២៩ពាន់តោន។

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ-ក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ៨៩,៥៨ពាន់ក្បាល ជ្រូកសាច់ចំនួន ១៥,២៥ពាន់ក្បាល ជ្រូកពូជ (មេ បា) ចំនួន ២,៣១ពាន់ក្បាល ស្វាក្តាមចំនួន ៩៨,២៧ពាន់ក្បាល ទឹកដោះគោចំនួន ២,៨៦ពាន់តោន ចំណីឆ្កែចំនួន ៤០,០៣ពាន់តោន រោមសត្វចំនួន ១៧២ តោន ស្បែកគោ-ក្របី ជ្រូកចំនួន ២៧,៦៨ពាន់តោន Gelatine ចំនួន ៨៤៨តោន និងកាកសំណល់ប្រេងឆាចំនួន ១២៦តោន។ ដោយឡែកនៅឆ្នាំ២០២៤ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ៣០,៨២ពាន់ក្បាល ជ្រូកពូជ (មេ បា) ចំនួន ៧៥០ក្បាល ស្វាក្តាមចំនួន ១១,៨៩ពាន់ក្បាល ចំណីឆ្កែចំនួន ១៤,២៦ពាន់តោន រោមសត្វចំនួន ៣២,៧៧ តោន ស្បែកគោ-ក្របី ជ្រូកចំនួន ១,៩៥ពាន់តោន Gelatine ចំនួន ៩៦តោន និងកាកសំណល់ប្រេងឆាចំនួន ១២៦ តោន។ ដោយឡែក សត្តឃាតដ្ឋានមានចំនួន ២៣៧កន្លែង ក្នុងនោះបានកែលម្អស្របតាមស្តង់ដារអនាម័យបច្ចេកទេស ចំនួន ១៥កន្លែង និងមានសត្តឃាតដ្ឋានទំនើបចំនួន ៥កន្លែង (បក្សី ៣កន្លែង និងជ្រូក ២កន្លែង)។

ក្រុមហ៊ុនសរុបចំនួន ២៥ បានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វចំនួន ៣០រោងចក្រ/កន្លែង បានផលិតចំណីសត្វប្រមាណ ១,៩លានតោនស្មើនឹង៥៤% នៃសមត្ថភាពផលិតរបស់រោងចក្រជាង ៣,៥លានតោន។ ក្រុមហ៊ុនមួយចំនួនទៀតបាននាំចូលចំណីសត្វចំនួន ១៧៦,៩៤ពាន់តោន វត្ថុធាតុដើមចំនួន ៧៤៨,៩៧ ពាន់តោន សារធាតុបន្ថែមចំនួន ៨៧,៩៨ពាន់តោន បសុឱសថចំនួន ២,៩៦ពាន់តោន វ៉ាក់សាំងចំនួន៧៤៨តោន សម្ភារៈបសុពេទ្យចំនួន ១១០តោន និងប្រតិករ ចំនួន ១,៤៦តោន។

### ១.២.៤. ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

- សហគមន៍នេសាទសរុបចំនួន ៥១៦សហគមន៍ (តំបន់ទឹកសាប ៤៧៥ និងតំបន់សមុទ្រ ៤១) មានសមាជិកសរុបចំនួន ៣៣២ ១៦៨នាក់ (ស្ត្រីប្រមាណ៣៥%) ត្រូវជា ១៤៧ ៥១៨គ្រួសារ។
- នេសាទទឹកសាបសម្រេចបានចំនួន ៤១៣,២ពាន់តោន ក្នុងឆ្នាំ២០២០ និងចំនួន ៤៦៧,៣ពាន់តោន នៅឆ្នាំ២០២៤។ នេសាទសមុទ្រសម្រេចបានចំនួន ១២២,៧ពាន់តោន ក្នុងឆ្នាំ២០២០ និងចំនួន ១៣៩,៣ពាន់តោន ក្នុងឆ្នាំ២០២៤។
- ឆ្នាំ២០២០ ផលវារីវប្បកម្មសម្រេចបានចំនួន ៤០០,៤ពាន់តោន និងឆ្នាំ២០២៤ ផលវារីវប្បកម្មសម្រេចបានចំនួន ៣២០,៣ពាន់តោន។

### ១.២.៥. ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

- បានវាយតម្លៃផ្ទៃដីគម្របព្រៃឈើ២០២២ មានទំហំ ៧ ២៨១ ៩០៥ហិកតា ស្មើនឹង ៤០,១០% នៃផ្ទៃដីសរុបទូទាំងប្រទេស
- ឆ្នាំ២០២៤ សហគមន៍ព្រៃឈើមានចំនួន ៦៥៥ គ្របដណ្តប់លើផ្ទៃដីសរុប ៥៣០ ៩៩៨ហិកតា និងមានសមាជិក ១៧២ ៣៩៨គ្រួសារ ក្នុងនោះ ក្រសួងបានទទួលស្គាល់សហគមន៍ចំនួន៥៤២ ដែលមានផ្ទៃដី ៤៥៥ ៦៤៩ហិកតា បានចុះកិច្ចព្រមព្រៀងបង្កើតសហគមន៍ចំនួន ៤៧១ ដែលមានផ្ទៃដីទំហំ ៣៨៦ ៤៨៥ហិកតា និងបានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ១២០ ដែលមានផ្ទៃដីទំហំ ៨៥ ៧៤៩ហិកតា
- ឆ្នាំ២០២៤ ដាំឈើក្នុងចម្ការឈើថ្មីទំហំ ២ ៧៤៨ហិកតា ក្នុងនោះ ដាំដោយរដ្ឋ ១៤៥ហិកតា ដាំដោយដៃគូសហការនិងប្រជាជនមានទំហំ ២ ៦០០ហិកតា និងដាំក្នុងពិធីរុក្ខទិវាទំហំ ៣ហិកតា។ បានដាំស្តារដើមចន្ទន៍ក្រស្នា សរុបចំនួន ២ ៥០០០ ដើម លើផ្ទៃដីទំហំ ១៧,៦៦ ហិកតា
- ក្រសួងបានបាននិងកំពុងសិក្សាវាយតម្លៃគម្របព្រៃឈើសម្រាប់ឆ្នាំ២០២៣ អនុវត្តបាន ៦៤,០៨% នៃផ្ទៃដីសរុបទូទាំងប្រទេស និងចាត់ថ្នាក់តាមរូបភាពផ្កាយរណបសម្រាប់ឆ្នាំ២០២៤ អនុវត្តបាន ៣៥% នៃផ្ទៃដីសរុបទូទាំងប្រទេស ព្រមទាំងបានចុះប្រមូលទិន្នន័យដើម្បីផ្ទៀងផ្ទាត់គម្របព្រៃឈើឆ្នាំ២០២៤ ជាក់ស្តែងបានចំនួន ១ ១៨៩ចំណុច។ និងកំពុងថែទាំចម្ការឈើសរុបទំហំ ៧៧៦ហិកតា ក្នុងនោះចម្ការពូជឈើទំហំ ១២០ហិកតា ឡូត៍បង្ហាញ កសិ-រុក្ខកម្មទំហំ ៣៧ហិកតា ចម្ការឈើដាំទំហំ ៥៩៧ហិកតា និងចម្ការរុក្ខទិវា៩កក្កដាសរុបទំហំ ៤០ហិកតា។

### ១.២.៦. ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន ៥ ៨៤០នាក់ ស្រី ១ ៥០៩នាក់ ស្មើនឹង២៥,៥៨% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន៣ ០៨៧នាក់ ស្រី ៩២០នាក់ ស្មើនឹង២៩,៧១% និងថ្នាក់រាជធានី ខេត្តមានចំនួន ២ ៧៥៣នាក់ ស្រី ៥៨៩នាក់ ស្មើនឹង ២១,០៣%។

ក្រសួងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការចំនួន ២ ៨៥៥នាក់ (ស្ត្រី ៨៤៤នាក់) ក្នុងនោះ ការបណ្តុះបណ្តាលក្នុងប្រទេស រយៈពេលខ្លី និងមធ្យម បានចំនួន២ ៥០៤នាក់ (ស្ត្រី ៧៤៣នាក់) និងរយៈពេលវែងចំនួន ១៥នាក់ ស្ត្រី ៥នាក់ និងការបណ្តុះបណ្តាលក្រៅប្រទេសសរុបបានចំនួន ៣៣៦នាក់ (ស្ត្រី ៩៦នាក់)។

ដោយឡែក នៅតាមគ្រឹះស្ថានអប់រំកសិកម្មទាំងបី មាននិស្សិតកំពុងសិក្សាសរុបចំនួន ៤ ៧៦០នាក់ (ស្ត្រី ២ ១១១នាក់) និងនិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បណ្ឌិតសរុបចំនួន ១ ២៣៦នាក់ (ស្ត្រី ៤៦៥នាក់)។

## ១.៣. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃ ជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការអនុវត្តគម្រោងសកម្មភាព និងសូចនាករសម្រាប់ផ្ទៀងផ្ទាត់លទ្ធភាពសម្រេចបាន ដែលនឹងត្រូវកំណត់នៅក្នុងផែនការ និងគម្រោងសកម្មភាពនីមួយៗ។ ដូច្នេះ ការតាមដាន និងវាយតម្លៃ ជាឧបករណ៍ដ៏ស័ក្តិសិទ្ធិសម្រាប់ផ្ទៀងផ្ទាត់ រាល់សូចនាករលទ្ធផលចុងក្រោយ សូចនាករលទ្ធផលក្នុងឆ្នាំ (Outcomes & Outputs) នៃផែនការយុទ្ធសាស្ត្រថវិកាថវិកាកម្មវិធី និងគម្រោងថវិកាប្រចាំឆ្នាំ ដែលជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្នុងការចូលរួមតាមដាន និងវាយតម្លៃ លើវឌ្ឍនភាពរបស់រាជរដ្ឋាភិបាល (ពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិ) នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០២៤-២០២៨។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផែនការ និងស្ថិតិ) បានដើរតួនាទីយ៉ាងសំខាន់ លើការអនុវត្តសកម្មភាពតាមដាន និងវាយតម្លៃ ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងគម្រោងផែនកាសកម្មភាព និងថវិកាប្រចាំផងដែរ។ គ្រប់អង្គភាពក្រោមឱវាទក្រសួង ដែលមានភារៈកិច្ចពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវវាយការណ៍ជូនក្រសួងពីលទ្ធផលសម្រេចបាន ឱ្យបានទៀងទាត់ទាន់ពេលវេលាតាមរយៈការផ្តល់របាយការណ៍ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ នាយកដ្ឋានផែនការ និងស្ថិតិ មានភារៈកិច្ច បូកសរុបរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលសម្រេចបាន រួចវាយការណ៍ជូនក្រសួង ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍។ ផ្អែកលើរបាយការណ៍នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវវាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ១.៤ បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលសម្រេចបានកន្លងមក វិស័យកសិកម្ម ក៏នៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួន ជាអាទិ៍៖

- ផលិតភាពនៃផលិតកម្មដំណាំនៅមានកម្រិត ការផ្ទេរបច្ចេកទេសនៅមិនទាន់ឆ្លើយតបតាមតម្រូវការរបស់កសិករ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្ម (ប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានដោយសន្សំសំចៃទឹក ផ្ទះសំណាញ់ ប្រព័ន្ធស្តុកទុក ឃ្លាំងសម្ងួត ឃ្លាំងត្រជាក់) នៅមិនទាន់មានគ្រប់គ្រាន់សម្រាប់ការធ្វើកសិកម្ម និងកសិ-ពាណិជ្ជកម្ម ការវិនិយោគលើការកែច្នៃកសិផល និងការប្រកួតប្រជែងទីផ្សារនៅមានកម្រិត
- ផលិតភាពនៃផលិតកម្មសត្វសម្រាប់កសិករខ្នាតតូចនៅមានកម្រិត ជាមួយនឹងថ្លៃដើមផលិតកម្មខ្ពស់ (ថ្លៃចំណីសត្វ ពូជសត្វ និងថ្នាំការពារ ព្យាបាលសត្វ) ធ្វើឱ្យការប្រកួតប្រជែងទីផ្សារសាច់សត្វជួបការលំបាក។ ការធ្វើផែនការផលិតកម្មសត្វដើម្បីផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញនៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ខ្ពស់។ ប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមានកម្រិត ការនាំចូលសត្វ និងផលិតផលសត្វខុសច្បាប់នៅតែបន្តកើតមាន។
- ការគ្រប់គ្រងធនធានជលផលនៅមានកម្រិត ការធ្វើនេសាទខុសច្បាប់នៅតែមាន ការរំលោភទន្រ្ទានកាន់កាប់ដីព្រៃលិចទឹក និងព្រៃកោងកាង ការការពារកន្លែងអភិរក្សជលផល។ ការធ្វើវារីវប្បកម្មចំណាយថ្លៃដើមខ្ពស់ ខ្វះហេដ្ឋារចនាសម្ព័ន្ធផលិតកម្មសម្រាប់គាំទ្រដល់ការរក្សាគុណភាព និងការអនុវត្តអនាម័យល្អ។

- ការថយចុះផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ការអនុវត្តច្បាប់នៅមានកម្រិត ការអាស្រ័យផលលើព្រៃឈើនៅមានភាពស្មុគស្មាញ ការផ្តល់ជម្រើសដល់ប្រជាពលរដ្ឋឱ្យចាប់យកមុខរបរកសិ-រុក្ខកម្ម ឬមុខរបរផ្សេងនៅមានកម្រិត ដើម្បីកាត់បន្ថយសម្ពាធមកលើធនធានព្រៃឈើ។

## ១.៥. ទិឆានការ

គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម បានចូលរួមក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា នឹងបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យកសិកម្ម ការអភិវឌ្ឍជនបទ ការជំរុញពាណិជ្ជកម្ម ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន និងការអភិវឌ្ឍទេសចរណ៍ ដែលមានវិធានការគន្លឹះដូចខាងក្រោម៖

១. បន្តធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម បង្កើនផលិតភាព ធ្វើពិពិធកម្ម អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធការអភិវឌ្ឍវិស័យកសិកម្ម គាំទ្រក្នុងខ្សែច្រវាក់តម្លៃកសិកម្ម លើកកម្ពស់សុវត្ថិភាពផលិតផលកសិកម្ម និងបង្កើនការនាំចេញ ដោយអនុវត្តឱ្យមានប្រសិទ្ធភាព នូវគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០។

២. បន្តពង្រឹងសមត្ថភាពផលិតដល់កសិករ និងសហគមន៍កសិកម្មពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់សម្រាប់ការកែច្នៃផលិតផលកសិកម្ម និងបង្កើនសមត្ថភាពកែច្នៃផលិតផលកសិកម្ម តាមរយៈ ការអនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបង្កើនការផ្សព្វផ្សាយអំពីការអនុវត្តបច្ចេកទេសកសិកម្មវៃឆ្លាត ធន់នឹងការប្រែប្រួលអាកាសធាតុ និងការជំរុញអនុវត្តកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី។

៣. បន្តអនុវត្តវិធានការបច្ចេកទេស សំដៅធានាឱ្យមានអាហារដែលមានសុវត្ថិភាព និងមានអាហារូបត្ថម្ភគ្រប់គ្រាន់ និងពង្រឹងប្រព័ន្ធស្បៀងអាហារ តាមរយៈ ការធ្វើទំនើបកម្មផលិតកម្មស្បៀងអាហារ ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងការអនុវត្តផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០ ។

៤. បន្តគាំទ្រការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម បង្កើនការផ្គត់ផ្គង់សាច់ លើកកម្ពស់សុខភាពសត្វ និងសុខុមាលភាពសាធារណៈ បង្កើនសមត្ថភាពស្រាវជ្រាវ និងមន្ទីរពិសោធន៍វិនិច្ឆ័យជំងឺសត្វ ពង្រឹងភាពជាដៃគូជាមួយសហគមន៍ចិញ្ចឹមសត្វ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

៥. រៀបចំយុទ្ធសាស្ត្រកសិកម្មអេឡិចត្រូនិក បង្កើតប្រព័ន្ធបច្ចេកទេសកសិកម្មតាមបែបឌីជីថល និងសម្របសម្រួលដល់ការប្រើប្រាស់វេទិកាឌីជីថលសម្រាប់កសិ-ធុរកិច្ច ព្រមទាំងពង្រីកសេវាកម្មព័ត៌មានទីផ្សារ កសិកម្មបែបឌីជីថល ឱ្យបានទូលំទូលាយដល់កសិករ ។

៦. បង្កើនការគ្រប់គ្រងធនធានព្រៃឈើ ដោយខិតខំជំរុញការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ ការរៀបចំផែនការអភិវឌ្ឍវិស័យព្រៃឈើនិងសត្វព្រៃ, ការបង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍព្រៃឈើសហគមន៍ ការអនុវត្តប្រព័ន្ធកសិរុក្ខកម្ម ការលើកកម្ពស់ការគ្រប់គ្រង និងអភិវឌ្ឍន៍សត្វព្រៃ និងជីវៈចម្រុះ ការជំរុញការដាំឈើឡើងវិញ ជាពិសេស ប្រភេទពូជឈើដែលមានតម្លៃសេដ្ឋកិច្ច។ បន្តការចុះបញ្ជីដីព្រៃឈើ និងដីព្រៃសហគមន៍ព្រៃឈើ បង្កើនការពិនិត្យតាមដានការអនុវត្តសម្បទានដីសេដ្ឋកិច្ច និងពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់។

៧. បន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល ពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍នេសាទ បង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម កែលម្អពូជត្រី និងអភិរក្សពូជត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់។ ជំរុញការអភិវឌ្ឍសមត្ថភាព និងបច្ចេកវិទ្យាកែលម្អគុណភាពផលិតផលជលផល ជំរុញវារីវប្បកម្ម និងចងក្រង

បណ្តុំវារីវប្បករ ដោយអនុវត្តនូវយន្តការផលិតកម្មវារីវប្បកម្មតាមកិច្ចសន្យា និងបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល ឱ្យមានប្រសិទ្ធភាពខ្ពស់។

៨. បន្តកែទម្រង់ការគ្រប់គ្រងស្ថាប័ន ពង្រឹងអភិបាលកិច្ច និងអភិវឌ្ឍន៍ធនធានមនុស្សស្របតាមគោលនយោបាយធនធានមនុស្សក្នុងវិស័យកសិកម្ម លើកកម្ពស់គុណភាពនៃការអប់រំកសិកម្ម តាមរយៈ ការអនុវត្តផែនការមេឆ្នាំ២០៣០ របស់គ្រឹះស្ថានអប់រំកសិកម្ម បង្កើតបណ្ឌិត្យសភាវិទ្យាសាស្ត្រកសិកម្ម និងបង្កើនសមត្ថភាពស្រាវជ្រាវសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា។

៩. បង្កើនសមត្ថភាពសេវាផ្សព្វផ្សាយបច្ចេកទេសលើជំនាញផ្នែកកសិកម្ម និង បណ្តុះបណ្តាលកសិករវ័យក្មេងជាមួយនឹងបច្ចេកវិទ្យាកសិកម្មថ្មីៗ និងឌីជីថល ដោយផ្សារភ្ជាប់រវាងការស្រាវជ្រាវ និងការផ្សព្វផ្សាយ តាមមុខជំនាញនីមួយៗ ឱ្យបានល្អប្រសើរ។ ពង្រីកបរិយាកាសគាំទ្រដល់អ្នកផលិត អ្នកកែច្នៃ និងអ្នកនាំចេញ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ តាមអភិក្រមរដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍" ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

## ២. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគោលបំណងគោលនយោបាយដូចខាងក្រោម៖

| គោលបំណងគោលនយោបាយ | មុំនៃយុទ្ធសាស្ត្របញ្ចកោណ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅក្នុង ផ.យ.អ.ជ |
|---|---|---|
| "ពង្រឹងប្រសិទ្ធភាពខ្សែច្រវាក់ផលិតកម្មកសិកម្ម ប្រកបដោយនិរន្តរភាព ដើម្បីធានាសន្តិសុខស្បៀងនិងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ" | មុំទី២ នៃយុទ្ធសាស្ត្របញ្ចកោណ | ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប្រកបដោយចីរភាព |
| | មុំទី៣ នៃយុទ្ធសាស្ត្របញ្ចកោណ | ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទដែលមានគោលដៅយុទ្ធសាស្ត្រ |
| | មុំទី៥ នៃយុទ្ធសាស្ត្របញ្ចកោណ | ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង |

រាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាព សំដៅធានាសុខសន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេស នៅក្នុងកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ ដូចខាងក្រោម៖

- កម្មវិធីអាទិភាពទី៥៖ ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទានសំដៅលើស្លួយផលិតកម្ម, រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យតាមរយៈ ការដាក់ចេញកញ្ចប់ថវិកាជាក់លាក់ ដោយចាប់ផ្ដើមពីចំនួន ១០០លានដុល្លារអាមេរិក និងអាចវិភាជថវិកាបន្ថែម, ប្រសិនបើមានតម្រូវការចាំបាច់, ដើម្បីធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលក្នុងការទិញ កសិផលពីប្រជាកសិករជាមួយនឹងគោលដៅរក្សា ស្ថិរភាពថ្លៃនៅរាល់រដូវប្រមូលផល, ជាពិសេសលើផលិតផលកសិកម្មមួយចំនួនជាអាទិ៍ ស្រូវ ស្វាយកែវរមៀត មៀនប៉ៃលិន ស្វាយចន្ទី ដំឡូង ពោត និងផលិតផលផ្សេងទៀតតាមការចាំបាច់។
- កម្មវិធីអាទិភាពទី៦៖ ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងជួយដល់គ្រួសារកសិករក្នុងការលើកស្ទួយ ផលិតផលកសិកម្មរបស់ខ្លួន។ រាជរដ្ឋាភិបាលនីតិកាលទី ៧ នឹងយកចិត្តទុកដាក់ផងដែរទៅលើការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ ដើម្បីរក្សាកម្លាំងរបស់កសិករក្នុងការផលិត ក៏ដូចជា ការតថ្លៃជាមួយអ្នកទទួលទិញ។

## ៣. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំ**កម្មវិធី** ចំនួន៣ ដូចខាងក្រោម៖

**កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម**

គោលបំណងរបស់កម្មវិធី៖ ជំរុញការផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងស្រុក និងការនាំចេញ តាមរយៈការបង្កើនផលិតភាពផលិតកម្មកសិកម្ម ក្នុងខ្សែច្រវាក់តម្លៃដំណាំ កៅស៊ូ សត្វ និងវារីវប្បកម្ម។

**កម្មវិធីទី២៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម**

គោលបំណងនៃកម្មវិធី៖ លើកកម្ពស់ការគ្រប់គ្រងធនធានជលផល និងព្រៃឈើ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

**កម្មវិធីទី៣៖ ការពង្រឹងស្ថាប័ន និងកិច្ចការទូទៅ**

គោលបំណងនៃកម្មវិធី៖ បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្ដល់សេវាគាំទ្រ និងការពង្រឹងសមត្ថភាពផ្នែកស្រាវជ្រាវ អប់រំ និងបណ្ដុះបណ្ដាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។

| បន្តធានាសន្តិសុខស្បៀងកម្ពុជាប្រកបដោយ និរន្តរភាព សេដ្ឋកិច្ច និងបរិស្ថាន ហើយកសិកម្មនៅតែចូលរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិ | | |
|---|---|---|
| កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម | កម្មវិធីទី២៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម | កម្មវិធីទី៣៖ ការពង្រឹងស្ថាប័ន និងកិច្ចការទូទៅ |

អនុកម្មវិធី/ចង្កោមសកម្មភាពសម្រាប់គាំទ្រដើម្បីសម្រេចបានគោលបំណងគោលនយោបាយ

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និង អង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| **ឈ្មោះគោលបំណងគោលនយោបាយ** | **ឈ្មោះ កម្មវិធី និង អនុកម្មវិធី** | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ | | | |
| | | | ឈ្មោះអង្គភាព | (១) | (២) | (៣) |
| «ពង្រឹងប្រសិទ្ធភាពខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព ដើម្បីធានាសន្តិសុខស្បៀងនិងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ» | ➢ កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម | ឯកឧត្តម យ៉ង់ សាំង កុមារ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | √ | | |
| | • អនុកម្មវិធីទី១.១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំ | ឯកឧត្តមងិន ឆាយ | អគ្គនាយកដ្ឋានកសិកម្ម (GDA) | √ | | |
| | • អនុកម្មវិធីទី១.២៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃសត្វ | ឯកឧត្តមតាន់ ផាន់ណារ៉ា | អគ្គនាយកដ្ឋានផលិតកម្ម និងសុខភាពសត្វ (GDAHP) | √ | | |
| | • អនុកម្មវិធីទី១.៣៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផល | ឯកឧត្តម ពុំ សុថា | រដ្ឋបាលជលផល (FiA) | √ | | |
| | • អនុកម្មវិធីទី១.៤៖ ការអភិវឌ្ឍធនធានព្រៃឈើ | ឯកឧត្តម សួន សុវណ្ណ | រដ្ឋបាលព្រៃឈើ (FA) | √ | | |
| | • អនុកម្មវិធីទី១.៥៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃសត្វកម្រ និងរុក្ខជាតិកម្រ (ថ្មី) | ឯកឧត្តម សរ ចិត្រា | អគ្គលេខាធិការដ្ឋាន (GS) | | | |
| | • អនុកម្មវិធីទី១.៦ ៖ ការរៀបចំខ្សែច្រវាក់ផលិតកម្មកសិកម្ម រាជធានី-ខេត្ត | ប្រធានមន្ទីរ | ២៥ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | √ | | |
| | ➢ កម្មវិធីទី២៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម | ឯកឧត្តម ចាន់ ចេស្តា | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | √ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | • អនុកម្មវិធីទី២.១៖ ការគ្រប់គ្រង ធនធានព្រៃឈើ និងសត្វព្រៃ | ឯឧ. សួន សុវណ្ណ | រដ្ឋបាលព្រៃឈើ (FA) | √ | | |
| | • អនុកម្មវិធីទី២.២៖ ការគ្រប់គ្រង និងអភិរក្សធនធានជលផល | ឯកឧត្តមពុំ សុថា | រដ្ឋាបាលជលផល (FiA) | √ | | |
| | • អនុកម្មវិធីទី២.៣៖ ការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយនិរន្តរភាព | ឯកឧត្តមងិន ឆាយ | អគ្គនាយកដ្ឋានកសិកម្ម | √ | | |
| | • អនុកម្មវិធីទី២.៤៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម រាជធានី-ខេត្ត | ប្រធានមន្ទីរ | ២៥ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | √ | | |
| | ➢ កម្មវិធីទី៣៖ ការពង្រឹងស្ថាប័ន និងកិច្ចការទូទៅ | ឯកឧត្តម នុត ច័ន្ទសុខា<br>ឯកឧត្តម គឹម សុន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | √ | | |
| | • អនុកម្មវិធីទី៣.១៖ ការគាំទ្រការអភិវឌ្ឍខ្សែច្រវាក់តម្លៃ (ថ្មី) | ឯកឧត្តម សរ ចិត្រា | អគ្គលេខាធិការដ្ឋាន | √ | | |
| | • អនុកម្មវិធីទី៣.២៖ ការគាំទ្រកិច្ចការទូទៅ | ឯកឧត្តម សរ ចិត្រា | អគ្គលេខាធិការដ្ឋាន | √ | | |
| | • អនុកម្មវិធីទី៣.៣៖ ការងារសវនកម្មផ្ទៃក្នុង | ឯកឧត្តម សរ ចិត្រា | អគ្គលេខាធិការដ្ឋាន | √ | | |
| | • អនុកម្មវិធីទី៣.៤៖ ការគាំទ្រផ្នែកស្រាវជ្រាវកសិកម្ម និងមន្ទីរពិសោធន៍ | ឯកឧត្តម សេន សុវណ្ណ | ១. អគ្គនាយកដ្ឋានកសិកម្ម<br>២.អគ្គនាយកដ្ឋានផលិតកម្ម និងសុខភាពសត្វ<br>៣. រដ្ឋបាលព្រៃឈើ<br>៤. រដ្ឋាបាលជលផល | √ | | |
| | • អនុកម្មវិធីទី៣.៥៖ លើកកម្ពស់គុណភាពពិសោធន៍ និងស្រាវជ្រាវកៅស៊ូ | លោក លិម ខាន់ទីវ៉ា | វិទ្យាស្ថានស្រាវជ្រាវ កៅស៊ូកម្ពុជា(IRCC) | √ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | • អនុកម្មវិធីទី៣.៦៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ បច្ចេកវិទ្យាកសិកម្ម | លោក ឡោ ប៊ុណ្ណា | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) | √ | | |
| | • អនុកម្មវិធីទី៣.៧៖ កែទម្រង់គុណភាពអប់រំ និងស្រាវជ្រាវកសិកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម | ឯកឧត្តម ង៉ោ ប៊ុនថាន | សាកលវិទ្យាល័យភូមិន្ទកសិកម្ម(RUA) | √ | | |
| | • អនុកម្មវិធីទី៣.៨៖ លើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | ឯកឧត្តម ឈុន គូរី | វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប (PNIA) | √ | | |
| | • អនុកម្មវិធីទី៣.៩៖ ពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកសិកម្មរបស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | ឯកឧត្តម ហែម វិរៈ | វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម(KNIA) | √ | | |
| | • អនុកម្មវិធីទី៣.១០៖ ការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស រាជធានី-ខេត្ត | ប្រធានមន្ទីរ | ២៥ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | √ | | |

*(*) ជាគោលការណ៍ ចំនួនគោលបំណងគោលនយោបាយ មិនត្រូវមានលើសពី ២ ឡើយ។ ក្នុងករណី ក្រសួង-ស្ថាប័នដែលមានមុខងារច្រើន អាចត្រូវបានអនុញ្ញាតឱ្យមាន គោលបំណងគោលនយោបាយលើសពី ២ ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និងឯកភាពជាមុនពី កសហវ ។*

*(**) ជាគោលការណ៍ ចំនួនកម្មវិធី មិនត្រូវមានលើសពី៥ ឡើយ។ ក្នុងករណីក្រសួង-ស្ថាប័នធំៗ ដែលមានមុខងារច្រើន អាចត្រូវបានអនុញ្ញាតឱ្យមានកម្មវិធីលើសពី៥ ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និងឯកភាពជាមុនពីកសហវ។*

*(***) សូមធីក (√) ដូចតទៅ៖ (១) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ (២) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និង (៣) មិនមែនជាអង្គភាពថវិកា។*

# ៤. ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម

## ៤.១. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកំណត់នូវសូចនាករនិងគោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាពនិងសមិទ្ធផលនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗដូចខាងក្រោម ៖

តារាង ១ "ក"

**ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី**

| សេចក្តីពណ៌នា (បន្ថែមជួរដេកមួយសម្រាប់សូចនាករចុងក្រោយ និងសូចនាករលទ្ធផលក្នុងឆ្នាំនីមួយៗ) | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំមុន (ឆ្នាំ២០២៤) | ឆ្នាំបច្ចុប្បន្ន (ឆ្នាំ២០២៥) | ឆ្នាំគ្រោងថវិកា (២០២៦) គោលដៅ | ឆ្នាំគ្រោងថវិកា (២០២៦) មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| ○ គោលបំណងគ.ប.៖ «ពង្រឹងប្រសិទ្ធភាពខ្សែច្រវាក់ផលិតកម្មកសិកម្ម ប្រកបដោយនិរន្តរភាពដើម្បីធានាសន្តិសុខស្បៀងនិងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ» | | | | | | | |
| **១.កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម** | 76,720.8 | | | | | | |
| *សូចនាករលទ្ធផលចុងក្រោយទី១.ក៖ តម្លៃផលិតផលកសិកម្មសរុប (ដំណាំ កៅស៊ូ ជលផល សត្វ) (លានដុល្លារ)* | | *11 783* | *12 151* | *12 516* | *ជំរុញការនាំចេញ និងសន្តិសុខស្បៀង* | *12 890* | *13 277* |
| *សូចនាករលទ្ធផលចុងក្រោយទី១.ខ៖ អនុបាតដែលអាចផ្គត់ផ្គង់ស្បៀងបានគ្រប់ គ្រាន់ដោយខ្លួនឯង (បន្លែ សាច់ ផលិតផលចាំបាច់)* | | *96.69%* | *96.91%* | *97.12%* | *សន្តិសុខស្បៀង* | *97.32%* | *97.50%* |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.១ អនុកម្មវិធីទី១.១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំ | 25,795.4 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ក៖ តម្លៃសេដ្ឋកិច្ចផលិតផលដំណាំនៅកសិដ្ឋាន (លានដុល្លារអាមេរិក)* | | *8 864* | *9 425* | *9 707* | *កំណើន ៣%* | *9 999* | *10 299* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ខ៖ ការនាំចេញផលិតផលដំណាំសរុប (លានដុល្លារអាមេរិក)* | | *5 068,5* | *4 688* | *4 779* | *កំណើន ៣%* | *4 870* | *5 016* |
| ១. ២ អនុកម្មវិធីទី១.២: ការអភិវឌ្ឍខ្សែច្រវាក់តម្លៃសត្វ | 16,122.1 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ១.២.ក៖ តម្លៃផលសត្វ និងផលិតផលសត្វ (លានដុល្លា)* | | *1 722* | *1 756* | *1 791* | *ក្នុងអត្រាកំណើន២%ក្នុង១ឆ្នាំ* | *1 827* | *1 864* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ១.២.ខ : តម្លៃការនាំចេញសត្វ និងផលិតផលសត្វ (លានដុល្លា)* | | *358* | *128* | *130* | | *132* | *135* |
| ១.៣ អនុកម្មវិធីទី១.៣៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផល | 2,648.1 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.ក៖ តម្លៃផលវារីវប្បកម្មទឹកសាប និងសមុទ្រ (លានដុល្លារ)* | | *740* | *700* | *700* | | *700* | *700* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.ខ៖ ការនាំចេញផលិតផលជលផល (លានដុល្លារ)* | | *9* | *9* | *9* | | *9* | *9* |
| ១.៤ អនុកម្មវិធីទី១.៤៖ ការអភិវឌ្ឍធនធានព្រៃឈើ | 1,519.4 | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.ក៖ ទំហំផ្ទៃដីត្រូវបានដាំឈើជាចម្ការ (រដ្ឋ ឯកជន និងដៃគូ)* | | *3 000* | *3 000* | *3 000* | | *3 000* | *3 000* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.ខ៖ ចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានចុះត្រួតពិនិត្យ និងវាយតម្លៃ* | | *50* | *50* | *50* | | *60* | *70* |
| ១.៥ អនុកម្មវិធីទី១.៥ ៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃសត្វ និងរុក្ខជាតិកម្រ | 42.0 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី១.៥.ក៖ តម្លៃសេដ្ឋកិច្ចនៃបរិមាណសត្វ និងរុក្ខជាតិដែលត្រូវបាននាំចេញ (លានដុល្លារ)* | | *NA* | *NA* | *45* | | *45* | *45* |
| ១.៦ អនុកម្មវិធីទី១.៦៖ ការរៀបចំខ្សែច្រវាក់ផលិតកម្មកសិកម្ម រាជធានី-ខេត្ត | 30,593.8 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ១.៦.ក៖ បរិមាណផលិតផលកសិកម្មដែលផលិតបានរបស់រាជធានី-ខេត្ត* | | | | | | | |
| **២.កម្មវិធីទី២៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម** | **62,894.2** | | | | | | |
| *សូចនាករលទ្ធផលក្រោយទី២.ក៖ ទំហំតំបន់គ្រប់គ្រងជលផលត្រូវបានការពារ និងគ្រប់គ្រង (លានហិកតា)* | | *9,6* | *9,6* | *9,6* | | *9,6* | *9,6* |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *សូចនាករលទ្ធផលក្រោយទី ២.ខ៖ ផលនេសាទចាប់ពីធម្មជាតិ(ទឹកសាប និងសមុទ្រ) មិនឱ្យលើសពី៦០០ពាន់តោន* | | *600* | *600* | *600* | | *600* | *600* |
| *សូចនាករលទ្ធផលក្រោយទី២.គ៖ ចំនួនសត្វព្រៃត្រូវបានថែរក្សា និងព្យាបាល (ក្បាល)* | | *3 000* | *3 000* | *3 000* | | *3 000* | *3 000* |
| *សូចនាករលទ្ធផលក្រោយទី២.ឃ៖ ទំហំផ្ទៃដីព្រៃត្រូវបានកំណត់ដើម្បីចុះបញ្ជីនិងគ្រប់គ្រង (ដីស្ថានីយ សហគមន៍ ដីសម្បទានសេដ្ឋកិច្ច)*<br>*(ហិកតា)* | | *17 000* | *20 000* | *20 000* | | *20 000* | *20 000* |
| ២.១.អនុកម្មវិធីទី២.១៖ ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ | 15,751.2 | | | | | | |
| *សូចនាករលទ្ធផលចុងក្រោយទី២.១.ក ៖ ទំហំផ្ទៃដីព្រៃត្រូវបានកំណត់ដើម្បីចុះបញ្ជី និងគ្រប់គ្រង (ដីស្ថានីយ៍ សហគមន៍ព្រៃឈើ និងសម្បទានដីសេដ្ឋកិច្ច)* | | *17 000* | *20 000* | *20 000* | | *20 000* | *20 000* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ខ ៖ ទំហំផ្ទៃដីត្រូវបានដាំឈើឡើងវិញ (រដ្ឋ និងឯកជន)*<br>*(ហិកតា)* | | *3 291* | *3 000* | *3 000* | | *3 000* | *3 000* |
| ២.២.អនុកម្មវិធីទី២.២៖ ការគ្រប់គ្រង និងអភិរក្សធនធានជលផល | 19,214.3 | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ២.២.ក៖ ផ្ទៃដីដែនគ្រប់គ្រងផលផលត្រូវបានការពារ និងគ្រប់គ្រង (លានហិកតា)* | | *9,56* | *9,56* | *9,56* | | *9,56* | *9,56* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ២.២.ខ៖ ផលនេសាទពីធម្មជាតិទឹកសាប (ពាន់តោន)* | | *500* | *450* | *450* | | *450* | *450* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី២.២.គ៖ ផលនេសាទពីធម្មជាតិសមុទ្រ (ពាន់តោន)* | | *100* | *100* | *130* | | *140* | *100* |
| អនុកម្មវិធីទី២.៣៖ ការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយនិរន្តរភាព | 344.8 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី២.៣.ក៖ចំនួនគ្រួសារកសិករដែលទទួលបានចំណេះដឹងបច្ចេកទេសស្តីពីការគ្រប់គ្រងដីនិងជីកសិកម្ម* | | *NA* | *1 139* | *2 526* | | *2 526* | *2 526* |
| អនុកម្មវិធីទី២.៤៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម រាជធានី-ខេត្ត | 27,583.9 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី២.៤.ក៖* បទល្មើសនេសាទ ព្រៃឈើ មានការថយចុះ | | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី២.៤.ខ៖* ចំនួនសហគមន៍ (នេសាទ ព្រៃឈើ) ត្រូវបានពង្រឹងលើការគ្រប់គ្រង | | | | | | | |
| **៣.កម្មវិធីទី៣៖ ការពង្រឹងស្ថាប័ន និងកិច្ចការទូទៅ** | **176,459.3** | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *សូចនាករលទ្ធផលចុងក្រោយទី៣.ក៖ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងការត្រួតពិនិត្យផ្ទៃក្នុង* | | *ត្រូវបានពង្រឹង* | *ត្រូវបានពង្រឹង* | *ត្រូវបានពង្រឹង* | | *ត្រូវបានពង្រឹង* | *ត្រូវបានពង្រឹង* |
| *សូចនាករលទ្ធផលចុងក្រោយទី៣.ខ៖ សេវាគាំទ្រទូទៅផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ* | | *ទាន់ពេល* | *ទាន់ពេល* | *ទាន់ពេល* | | *ទាន់ពេល* | *ទាន់ពេល* |
| *សូចនាករលទ្ធផលចុងក្រោយទី៣.គ៖ ចំនួនអ្នកទទួលបាននូវបច្ចេកទេសកសិកម្មស្តីពី ការលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពកសិផល (ផលិតកម្មដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ការកែច្នៃ ការរៀបចំសហគមន៍សិកម្មទំនើប មន្ត្រីកសិកម្មឃុំ)* | | *9 190* | *532 125* | *642 732* | *បង្កើនការផ្តល់សេវាបច្ចេកទេសកសិកម្ម* | *642 980* | *643 228* |
| ៣.១.អនុកម្មវិធីទី៣.១៖ ការគាំទ្រការអភិវឌ្ឍខ្សែច្រវាក់តម្លៃ | 5,013.7 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ៣.១.ក៖ ប្រសិទ្ធភាពនៃការសម្របសម្រួលថ្លៃកសិផល (ស្រូវ ស្វាយចន្ទី បន្លែ...)* | | *95* | *95* | *95* | | *95* | *95* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ៣.១.ខ៖ ចំនួនសហគមន៍កសិកម្មទំនើប* | | | | *3* | *កម្មវិធីគោនយោបាយអាទិភាព៥ និងទី៦* | *3* | *3* |
| ៣.២.អនុកម្មវិធីទី៣.២៖ ការគាំទ្រកិច្ចការទូទៅ | 93,530.8 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.២.ក៖ ប្រសិទ្ធភាពនៃការអនុវត្តសមិទ្ធិកម្ម (%)* | | *95.82* | *95* | *95* | | *95* | *95* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.២.ខ៖ប្រសិទ្ធភាពនៃការអនុវត្តថវិកា ធៀបច្បាប់ហិរញ្ញវត្ថុ (+/-5%)* | | *91* | *95* | *96* | | *96* | *96* |
| ៣.៣ អនុកម្មវិធីទី៣.៣: ការងារសវនកម្មផ្ទៃក្នុង | 384.4 | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ៣.៣.កៈ អត្រា(%)នៃការអនុវត្តអនុសាសន៍* | | *58* | *60* | *62* | | *64* | *66* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ៣.៣.ខៈ ចំនួនអង្គភាពធ្វើអធិការកិច្ចរួច និងបានកែលម្អការអនុវត្តស្របតាមច្បាប់ និងកាត់បន្ថយនូវបាតុភាពអសកម្ម* | | *15* | *10* | *10* | | *12* | *14* |
| ៣.៤ អនុកម្មវិធីទី៣.៤៖ ការគាំទ្រផ្នែកស្រាវជ្រាវកសិកម្ម និងមន្ទីរពិសោធន៍ (ថ្មី) | 3,387.4 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៤.កៈ របាយការណ៍ស្តីពីលទ្ធផលនៃការស្រាវជ្រាវ និងពិសោធន៍ ដំណាំ ផលិតកម្មសត្វ ជលផល និងព្រៃឈើ* | | *NA* | *NA* | *4* | | *4* | *4* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៤.ខៈ ចំនួនសំណាកត្រូវបានវិភាគនៅក្នុងមន្ទីរពិសោធន៍* | | *16 520* | *19 460* | *19 390* | | *24 610* | *24 540* |
| ៣.៥.អនុកម្មវិធីទី៣.៥៖ លើកកម្ពស់គុណភាពពិសោធន៍ និងស្រាវជ្រាវកៅស៊ូ | 2,618.0 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៥.កៈ ចំនួនពូជកៅស៊ូបង្កើតថ្មី* | | *1* | *1* | *1* | | *1* | *1* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៥.ខៈ ចំនួន Clone កៅស៊ូ ដែលបានអភិវឌ្ឍន៍ អភិរក្ស និងគ្រប់គ្រង* | | *78* | *80* | *82* | | *84* | *86* |
| ៣.៦ អនុកម្មវិធីទី៣.៦៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម | 6,306.0 | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៦.កៈ ចំនួនពិសោធន៍បង្ហាញត្រូវបានអនុវត្ត(ចំនួនពិសោធន៍)* | | *13* | *5* | *200* | *កែសម្រួលសូចនាករ* | *200* | *200* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៦.ខៈ ប្រភេទពូជដំណាំថ្មីៗត្រូវបានស្នើបញ្ចេញជាផ្លូវការ(ចំនួនពូជ)* | | *1* | *1* | *1* | | *1* | *1* |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៦.គៈ បរិមាណគ្រាប់ពូជដំណាំស្រូវដែលមានភាពសុទ្ធខ្ពស់(Genetic Purity) និងគុណភាពល្អ (Germination Rate)ត្រូវបានផលិត(តោន)* | | *236,2* | *170* | *170* | *ផលិតពូជស្រូវដែលមានចំណាត់ថ្នាក់ខ្ពស់ពីពូជវិញ្ញាបនបត្រមកពូជចុះបញ្ជី។* | *170* | *170* |
| ៣.៧.អនុកម្មវិធីទី៣.៧៖ កែទម្រង់គុណភាពអប់រំ និងស្រាវជ្រាវកសិកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម | 5,908.0 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ៣.៧កៈ ចំនួននិស្សិតបញ្ចប់ការសិក្សាគ្រប់កម្រិត* | | *620* | *630* | *640* | *អនុវត្តយុទ្ធសាស្ត្រថ្មី* | *650* | *660* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ៣.៧ខៈ ចំនួនអត្ថបទវិទ្យាសាស្ត្រត្រូវបានបោះពុម្ព* | | *0* | *4* | *5* | *អនុវត្តយុទ្ធសាស្ត្រថ្មី* | *6* | *7* |
| ៣.៨ អនុកម្មវិធីទី៣.៨៖ លើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | 4,865.0 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ៣.៨ក ៖ ចំនួននិស្សិតបញ្ចប់ការសិក្សាគ្រប់កម្រិត* | | *296* | *មិនទាន់ចប់ឆ្នាំ* | *300* | | *325* | *350* |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំ៣.៨.ខ៖ ចំនួនអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រត្រូវបានបោះពុម្ព* | | *3* | *3* | *4* | | *5* | *7* |
| ៣.៩.អនុកម្មវិធីទី៣.៩៖ ពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស ក្នុងវិស័យកសិកម្មរបស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | 3,842.0 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៩.ក៖ ចំនួននិស្សិតបានបញ្ចប់ការសិក្សា* | | *119* | *160* | *160* | | *165* | *170* |
| ៣.១០.អនុកម្មវិធីទី៣.១០៖ ការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស រាជធានី-ខេត្ត | 50,604.0 | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ៣.១០ក៖ ប្រសិទ្ធភាពនៃការអនុវត្តថវិកាសមិទ្ធ* | | *95* | *95* | *95* | | *95* | *95* |

(*) *កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន៥។*

### ៤.២. ទម្រង់របាយការណ៍ក្របខ័ណ្ឌថវិកាសមិទ្ធកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបំពេញព័ត៌មានលម្អិត អំពីសូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយ ដូចក្នុងទម្រង់ "ក" នៃតារាងទី ២ "ក" ។ ក្នុងករណីក្រសួង-ស្ថាប័នស្នើសុំផ្លាស់ប្តូរ ឬធ្វើបច្ចុប្បន្នភាពលើរចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម (រចនាសម្ព័ន្ធកម្មវិធី និង សូចនាករសមិទ្ធកម្ម) ដូចជា៖ ការបន្ថែម ការកែសម្រួល ឬការដកចេញនូវកម្មវិធីអនុកម្មវិធី ឬចង្កោមសកម្មភាព ក្រសួង-ស្ថាប័នត្រូវបំពេញទម្រង់ "ខ" នៃតារាងទី ៦ "ក" ដោយត្រូវធ្វើការបញ្ជាក់ ឬពន្យល់អំពីមូលហេតុនៃ ការផ្លាស់ប្តូរ និងត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាចាំបាច់។ នៅពេលដែលមានការយល់ ព្រមលើការផ្លាស់ប្តូររចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបំពេញតារាងរចនាសម្ព័ន្ធ ថវិកាសមិទ្ធកម្មឡើងវិញដែលមានភ្ជាប់ជាទម្រង់ "គ" នៃតារាងទី ៧ "ក" ដែលជាតារាងសមាសធាតុសង្ខេប នៃរចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម។ ទម្រង់នេះ គឺជាផ្នែកមួយក្នុងការបង្ហាញពីអង្គភាព និងអ្នកទទួលខុសត្រូវរបស់កម្មវិធី និងអនុកម្មវិធី។

**តារាង ២ "ក"**

**ទម្រង់បែបបទសូចនាករសមិទ្ធកម្មកម្មវិធី**
**របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៦ ទម្រង់ "ក"**

| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម** | **អង្គភាពទទួលបន្ទុក៖ កសក** | **កាលបរិច្ឆេទ៖ ២០២៥** |
|---|---|---|---|
| **គោលបំណងនៃកម្មវិធី៖** ជំរុញការផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងស្រុក និងការនាំចេញ តាមរយៈការបង្កើនផលិតភាពផលិតកម្មកសិកម្ម ក្នុងខ្សែច្រវាក់តម្លៃដំណាំ កៅស៊ូ សត្វ និងវារីវប្បកម្ម។ | | | |
| ប្រភេទសូចនាករ៖ ☒ **សូចនាករលទ្ធផលចុងក្រោយ** | | លេខកូដសូចនាករ៖ ☒ KPI ១.ក (សម្រាប់កម្មវិធី) | |
| ***ឈ្មោះសូចនាករវែង៖*** *តម្លៃផលិតផលកសិកម្មសរុប (ដំណាំ កៅស៊ូ ជលផល សត្វ) (លានដុល្លារ)* | | | |
| ***ឈ្មោះសូចនាករខ្លី៖*** *តម្លៃផលិតផលកសិកម្ម* | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ដើម្បីវាស់វែងនូវបរិមាណផលិតផលកសិកម្មសម្រាប់ធានាសន្តិសុខស្បៀង ដែលត្រូវផ្គត់ផ្គង់ឱ្យស្របតាមតម្រូវការហូបចុកគ្រប់គ្រាន់ក្នុងស្រុក (ស្រូវ បន្លែ ផ្លែឈើ ត្រី សាច់) | | | |
| **សេចក្តីពណ៌នា៖** បរិមាណនៃការផ្គត់ស្រូវ បន្លែ ផ្លែឈើ ត្រី សាច់ សម្រាប់ការហូបរបស់ប្រជាជនកម្ពុជា និងភ្ញៀវទេសចរណ៍។ | | | |
| **ការគណនា៖** តម្រូវការស្បៀងដោយផ្អែកលើបទដ្ឋានរបស់អង្គការស្បៀងនិងកសិកម្ម នៃសហប្រជាតិ (FAO) | | | |
| **ប្រភពទិន្នន័យ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង FAO | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ឆ្នាំ២០២៥ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ខែមីនា ឆ្នាំ២០២៥ | | | |

**តារាង ២ "ក"**

**ទម្រង់បែបបទសូចនាករសមិទ្ធកម្មអនុកម្មវិធី**
**របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៦ ទម្រង់ "ក"**

| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម** | **អង្គភាពទទួលបន្ទុក៖ កសក** | **កាលបរិច្ឆេទ៖ ២០២៥** |
|---|---|---|---|
| **គោលបំណងនៃកម្មវិធី៖** ជំរុញការផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងស្រុក និងការនាំចេញ តាមរយៈការបង្កើនផលិតភាពផលិតកម្មកសិកម្ម ក្នុងខ្សែច្រវាក់តម្លៃដំណាំ កៅស៊ូ សត្វ និងវារីវប្បកម្ម។ | | | |
| ប្រភេទសូចនាករ៖ ☑ សូចនាករលទ្ធផលចុងក្រោយ | | លេខកូដសូចនាករ៖ ☑ KPI ១.ខ (សម្រាប់កម្មវិធី) | |
| ***ឈ្មោះសូចនាករវែង៖*** *អនុបាតដែលអាចផ្គត់ផ្គង់ស្បៀងបានគ្រប់ គ្រាន់ដោយខ្លួនឯង (បន្លែ សាច់ ផលិតផលទាំពាច់)* | | | |
| ***ឈ្មោះសូចនាករខ្លី៖*** *ផ្គត់ផ្គង់ស្បៀង* | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** បង្ហាញពីទំនាក់ទំនងរវាងទំហំផលិតកម្មនិងការប្រើប្រាស់ក្នុងស្រុក ពោលគឺ ជាវិសាលភាពដែលការផ្គត់ផ្គង់ទំនិញរបស់ប្រទេសមួយបានមកពីផលិតកម្មក្នុងស្រុករបស់ខ្លួន ឬវិសាលភាពដែលប្រទេសមួយពឹងផ្អែកលើផលិតកម្មរបស់ខ្លួន។ ការជ្រើសរើសផ្ដោតលើ ផលិតផលសំខាន់ ៣គឺ បន្លែ ត្រី និងសាច់។ | | | |
| **សេចក្ដីពណ៌នា៖** សូចនាករនេះបើការគណនាឃើញអត្រាតិចជាង ១០០ ភាគរយបង្ហាញពី ភាពមិនគ្រប់គ្រាន់នៃផលិតកម្មស្បៀង ដើម្បីបំពេញតម្រូវការរបស់ប្រជាជន។ បើស្មើ១០០ ភាគរយ បង្ហាញថាសមត្ថភាពផលិតស្បៀងនៃវិស័យនេះគឺគ្រប់គ្រាន់។ អត្រាលើសពី ១០០ ភាគរយ បង្ហាញថាផលិតកម្មក្នុងស្រុកគឺច្រើនជាងតម្រូវការក្នុងស្រុក។ | | | |
| **ការគណនា៖** អនុបាតដែលអាចផ្គត់ផ្គង់ស្បៀងបានគ្រប់គ្រាន់ដោយខ្លួនឯង = ផលិតកម្ម ÷ (ផលិតកម្ម + ការនាំចូល − ការនាំចេញ) x ១០០ ។ | | | |
| **ប្រភពទិន្នន័យ៖** ទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | | | |
| ថ្ងៃកំណត់នៃទិន្នន័យ៖ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | | |
| កាលបរិច្ឆេទកែប្រែចុងក្រោយ៖ ខែមីនា ឆ្នាំ២០២៥ | | | |

**តារាង ៣ "ក"**

## ទម្រង់បែបបទសូចនាករសមិទ្ធកម្មអនុកម្មវិធី
## របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៦ ទម្រង់ "ក"

| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុកម្មវិធី១.១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំ | អង្គភាពទទួលបន្ទុក៖ អគ្គនាយកដ្ឋានកសិកម្ម | កាលបរិច្ឆេទ៖ ២០២៥ |
|---|---|---|---|

**គោលបំណងអនុកម្មវិធី៖** បង្កើនបរិមាណ គុណភាព និងសុវត្ថិភាពនៃផលិតកម្មដំណាំ ដើម្បីរក្សាសន្តិសុខស្បៀង និងស្ថិរភាពតម្លៃ ផ្គត់ផ្គង់ការកែច្នៃ និងនាំចេញ។

| ប្រភេទសូចនាករ÷ | លេខកូដសូចនាករ÷ |
|---|---|
| ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | លេខកូដសូចនាករ៖ ☑ PI ១.១.ក (សម្រាប់អនុកម្មវិធី) |

***ឈ្មោះសូចនាករវែង៖*** *តម្លៃសេដ្ឋកិច្ចផលិតផលដំណាំនៅកសិដ្ឋាន (លានដុល្លារអាមេរិក)*

***ឈ្មោះសូចនាករខ្លី៖*** *ផលិតផលដំណាំ តម្លៃសេដ្ឋកិច្ច*

**គោលបំណង/សារៈសំខាន់នៃសូចនាករ៖** សូចនាការនេះនឹងបង្ហាញអំពីបម្រែបម្រួលទំហំថវិកាសរុបពីមួយឆ្នាំទៅមួយឆ្នាំ ដែលអនុវិស័យដំណាំទទួលបានពីបរិមាណផលគ្រប់មុខដំណាំនៅកម្រិតកសិដ្ឋាន។

**សេចក្តីពណ៌នា៖** តម្លៃសេដ្ឋកិច្ចនៅកម្រិតកសិដ្ឋាន គឺប្រែប្រួលទៅតាមតម្លៃមធ្យមក្នុងមួយឯកតាតម្លៃនៃកសិផលនីមួយៗ។ នៅពេលតម្លៃក្នុងមួយឯកតាកើនឡើង បើទោះជាបរិមាណផលនៅដដែល ឬកើនឡើង ក៏តម្លៃសេដ្ឋកិច្ចសរុបកើនឡើងដែរ ប៉ុន្តែបើតម្លៃក្នុងមួយឯកតាថយចុះ ទោះជាបរិមាណផលកើនឡើង ក៏មិនប្រាដកថាតម្លៃសេដ្ឋកិច្ចសរុបកើនឡើងនោះទេ។

